# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**យូនីត (ខេមបូឌា) ខូអេលធីឌី**
**U-KNITS (CAMBODIA) CO., LTD**

អាស័យដ្ឋាន: ផ្លូវជាតិលេខ២ ភូមិព្រែកហូរលិច សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្ដាល

## កិច្ចព្រមព្រៀង

ស្ដីពីការប្រជុំពិភាក្សាលើករណីស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតរយៈពេល០១ខែ គឺចាប់ពីថ្ងៃទី០៤ ខែឧសភា ដល់ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២០

*អង្គប្រជុំបានឯកភាព និងព្រមព្រៀងដូចខាងក្រោម ៖*

នៅថ្ងៃព្រហស្បត្តិ៍៨កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០ វេលាម៉ោងដប់បីរសៀល មានកិច្ចប្រជុំមួយនៅ ក្រុមហ៊ុន យូនីត (ខេមបូឌា) ខូ.,អេលធីឌី ដែលមានអាស័យដ្ឋានស្ថិតនៅភូមិព្រែកហូរលិច សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្ដាល ដែលមានកម្មករសរុប ១១០៦ (ស្រី៨៧៨) ដែលមានលោកស្រី JI SEUNG HEE ជាអ្នកគ្រប់គ្រងទូទៅ តំណាងអោយលោក SOHN CHHON IK ជនជាតិកូរ៉េ ជានាយកក្រុមហ៊ុនកាត់ដេរសំលៀកបំពាក់ បានចូលរួមប្រជុំពិភាក្សាលើករណីស្ដីពីការស្នើសុំព្យួរកិច្ចសន្យាការងារកម្មករចំនួន០១ខែ ។

ជាកិច្ចចាប់ផ្ដើមលោកស្រី JI SEUNG HEE ជាប្រធានអង្គប្រជុំបានបើកកិច្ចប្រជុំនិងថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅដល់អស់លោកលោកស្រីដែលបានអញ្ជើញចូលរួមប្រជុំថ្ងៃនេះ បន្ទាប់មកលោកប្រធាន អង្គប្រជុំបានមតិសម្របសម្រួលអំពី ករណីខាងលើ និងពន្យល់ពីមូលហេតុដោយសារតែក្រុមហ៊ុនកង្វះការបញ្ជាទិញក្នុងអំឡុងពេលផ្ទុះមេរោគកូវីត១៩ ដូច្នេះក្រុមហ៊ុន យូនីត (ខេមបូឌា) ខូ.,អេលធីឌី និងតំណាងប្រតិភូបុគ្គលិក និងសហជីពនៃកម្មករនិយោជិតទាំងអស់បានព្រមព្រៀងគ្នាដូចខាងក្រោម:

១. ឯកភាពព្យួរកិច្ចសន្យាការងារកម្មករចំនួន ១៤៩ នាក់ រយ:ពេល០១ខែ ដោយគិតចាប់ពីថ្ងៃទី០៤ ខែឧសភា រហូតដល់ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២០។

២. ក្នុងអំឡុងពេលនៃការព្យួរកិច្ចសន្យាការងារនេះក្រុមហ៊ុនបានព្រមព្រៀង ផ្ដល់ប្រាក់ឧបត្ថមជូន កម្មករនិយោជិត គឺស្មើនឹង៣០ដុល្លារអាមេរិចសម្រាប់ម្នករម្នាក់ៗក្នុង១ខែ។

ថ្ងៃព្រហស្បត្តិ៍៨កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

តាខ្មៅ, ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ២០២០

បានឃើញ និងឯកភាព

**តំណាងសហជីព**

- ម៉ន យុទ្ធា
- អែម វណ្ណា

បានឃើញ និងឯកភាព

**ប្រតិភូបុគ្គលិក (តំណាងកម្មករ)**

- ម៉ែន ចិន្ដា
- ហ៊ុន ចាន់រី
- ស៊ុំ ស្រីពេជ្រ
- ជា ចាន់លាប
- លុន សុខរ៉ន
- ម៉ាយ សេដា
- សុត ណារិន
- ម៉ន យុទ្ធា
- ប៉ែន សារិទ្ធ
- ផន្ទ លីដា
- សោម ស្រីខួច

**នាយកក្រុមហ៊ុន**

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន យូនីត (ខេមបូឌា) U-KNITS (CAMBODIA) Co., LTD.

JI SEUNG HEE